





# ការអភិរក្សធនធាន បឹងទន្លេសាប និង តំបន់ឆ្នេរ

គម្រោងរយៈពេល៣ឆ្នាំ(២០០៨-២០១០) នៅក្នុងប្រទេសកម្ពុជាបង្កើតឡើងក្នុងភាពជាដៃគូរវាង អង្គការគម្រោងសកម្មភាពព្រៃកោងកាង (MAP) ប្រចាំតំបន់អាស៊ី (MAP -Asia) និងគំរោងការចូលរួមគ្រប់គ្រងធនធានតំបន់ឆ្នេរ (PMCR) នៃក្រសួងបរិស្ថានរួមជាមួយអង្គការក្នុងស្រុកឈ្មោះថា អភិវឌ្ឍន៍ និងបច្ចេកទេសសមស្រប (DATe) ។ គម្រោងសហប្រតិបត្តិការទាំងពីរនេះមានគោលបំណងលើកកំពស់ស្ថានភាពចិញ្ចឹមជីវិតរបស់ប្រជានេសាទតាមរយៈការពង្រឹងការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រជាសហគមន៍ពឹងផ្អែកទៅលើធនធានធម្មជាតិជាចំបងក្នុងជីវភាពរស់នៅ ។អង្គការMAP-Asia មានតួនាទីជាអ្នកត្រួតពិនិត្យ ការអនុវត្ត ធ្វើការតាមដាន និងវាយតំលៃទៅលើគម្រោងដៃគូទាំងពីរ នៅពេល ដែលគម្រោង PMCR និង DATe គឺជាសាម៉ីគម្រោងដែលធ្វើការអនុវត្តផ្ទាល់ ។ មូលនិធិ នៃសហរដ្ឋអាមេរិកគឺជាអ្នកផ្តល់នូវការ គាំទ្រ ផ្នែកថវិកាសម្រាប់គម្រោងជំហ៊ានទី២នេះ ។

## កម្មវិធីសំខាន់ៗរបស់ដៃគូគម្រោង

អង្គការ MAP-Asia បានបង្កើតឡើងនៅខែមិនា ឆ្នាំ១៩៩២ ដោយលោក Alfredo Quarto ពេលត្រឡប់មកពីសហរដ្ឋអាមេរិកក្នុងដំណើរអង្កេតពីប្រទេសថៃទៅប្រទេសម៉ាឡេស៊ីក្នុងគោលបំណងសរសេរពីបញ្ហាបរិស្ថានទាំងឡាយនៅក្នុងដំណើរការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សនៃពិភពលោក ។ ដោយយល់ឃើញថាសកម្មភាពទាំងនេះជាការបំផ្លាញព្រៃកោងកាងនៅតាមតំបន់ឆ្នេរតាមរយៈឧស្សាហកម្មស្រែបង្គា និងបញ្ហាប្រឈមនានាដែលតែងតែកើតមាននៅតាមសហគមន៍តំបន់ឆ្នេរ ។ ដូច្នេះទើបកិច្ចការពារធនធានតំបន់ឆ្នេរដែលជាប្រភពនៃការចិញ្ចឹមជីវិតផ្អែកសំខាន់ លើការនេសាទជាលក្ខណៈគ្រួសារត្រូវបានបំផុសឡើង ។

## ការងាររបស់ MAP ផ្តោតសំខាន់ដូចខាងក្រោម :

- ការតស៊ូមតិ
- ការអប់រំ និង បង្កើនចំណេះដឹង
- កិច្ចសហការ និង បណ្តាញការងារ
- ការអភិរក្ស និងការស្តារឡើងវិញ
- ការគ្រប់គ្រងធនធានធម្មជាតិតាមបែបសហគមន៍
- គំនិតផ្តួចផ្តើមក្នុងការបង្កើតសហគមន៍តាមរយៈជម្រើសផ្សេងៗ

## ការងារ DATe (ទន្លេសាប_កំពង់ឆ្នាំង) :

គោលដៅរួម និងវត្ថុបំណងនៃគំរោងនេះ គឺដើម្បីធ្វើឱ្យប្រសើរឡើងនូវមុខរបរចិញ្ចឹមជីវិត របស់អ្នកភូមិតាមរយៈការផ្សព្វផ្សាយនូវជំរើសសមស្របដើម្បីធ្វើការផ្លាស់ប្តូរនិងអភិរក្សធនធានទាំងឡាយនៅតាមតំបន់បឹងទន្លេសាប និង តំបន់ឆ្នេរ ។ សកម្មភាពសំខាន់ៗរួមមាន:

- ផ្សព្វផ្សាយចង្រ្កានកែច្នៃ
- ចង្រ្កានត្រីឆ្អើរ
- ផលិតជីកំប៉ុសធ្វើពីកំប្លោក
- កែច្នៃគុណភាពធ្យូង ដែលផលិតពីដើមបន្លាអួយយ៉ះ
- បង្កើតកន្លែងប្រមូលប្រេងម៉ាស៊ីនចាស់ៗពីទូក-ជលយានយន្ត(កាណូត)
- ការដាំព្រៃលិចទឹកឡើងវិញ







## ការងារ PMCR (តំបន់ឆ្នេរ_កោះកុង) :

គម្រោង PMCR គឺជាគម្រោងសិក្សាស្រាវជ្រាវដោយឆ្ពោះទៅរកការអនុវត្តជាក់ស្តែង ដែលបានចាប់ផ្តើមឡើងក្នុងឆ្នាំ១៩៩៧។ គម្រោងនេះបង្កើតឡើងដើម្បីបញ្ចៀសនូវផលប៉ះពាល់ទាំងឡាយចំពោះប្រព័ន្ធអេកូឡូស៊ីនៅតាមតំបន់ឆ្នេរ តាមរយៈប្រសិទ្ធភាព ការអប់រំ-កិច្ចសហការ-ការអភិរក្សធនធាន និង ការសិក្សាដោយអនុវត្ត ។ គោលការណ៍សំខាន់នៃគម្រោងនេះ គឺដើម្បីលើកកំពស់សិទ្ធិ និងពង្រឹងអំណាចចំពោះការចូលរួមគ្រប់គ្រងធនធានធម្មជាតិរបស់ប្រជាពលរដ្ឋ ក្នុងការធានាឱ្យមាននិរន្តរភាពនៃការគ្រប់គ្រងបរិស្ថាននៅតាមតំបន់ឆ្នេរ ។

## សកម្មភាពជាអាទិភាពចំបងៗ ដែលគំរោង PMCR លើកយកមកអនុវត្ត រួមមានដូចជា:

- ប្រមូលឯកសារធ្វើការកំណត់វិភាគ និងរៀបចំនូវ សំភារៈ ឯកសារសិក្សា អប់រំពីបណ្តាមជ្ឈមណ្ឌលធនធានជាគោលដៅសំរាប់បើកទូលាយដល់អ្នកអានទូទៅ ។
- បង្កើតនូវយន្តការដ៏មានប្រសិទ្ធិភាព និងគុណភាពនូវធនធានឯកសារសម្រាប់ជាជំនួយដល់អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត
- បង្កើនចំណេះដឹងពីសារៈសំខាន់នៃបរិស្ថានធម្មជាតិ ជាមួយនិងការចិញ្ចឹមជីវិតនៅតាមតំបន់រស់នៅ និង និរន្តរភាពនៃការ ប្រើប្រាស់ធនធានទាំងនោះ ។
- លើកទឹកចិត្តដល់អ្នកទន់ខ្សោយ និង ធ្វើការឆ្ពោះទៅរកតុល្យភាពយេនឌ័រនៅគ្រប់សកម្មភាព ដែលបង្កើតឡើង ។
- បង្កើននូវទំនាក់ទំនង និងការទទួលខុសត្រូវរួមគ្នារវាង រាជរដ្ឋាភិបាល-អជ្ញាធរដែនដី និងប្រជាពលរដ្ឋនៅតាមសហគមន៍ ក្នុងការធ្វើឱ្យមាននិរន្តរភាពនៃការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិ ។




## Contact Us @

MAP.Cambodia@gmail.com
date_admin@online.com.kh
pmmr@online.com.kh